ប្រធានមន្ទីរ អប់រំយុវជននិងកីឡា ខេត្តតាកែវ និង នាយកវិទ្យាល័យ **ជា ស៊ីម** តាកែវ មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**គា សាហាន**

* * *

ភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

**ប្រកាសលេខ: ៣៣០ អយក.ប្រ.ក**

**ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា ចំនួ សារុន ស្មោះខ្ចី**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវលេខ ១៥៦៩ អយកត.បឋម ចុះថ្ងៃទី ២២-៣-៩៦ ដោយមានចំណារឯកភាពរបស់អភិបាលខេត្តរងទី ២ លេខ ៤៧៣ លខ.បជ ចុះថ្ងៃទី ២២-៣-៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ ១** :អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡា ខេត្តតាកែវ ប្តូរឈ្មោះសាលាបឋមសិក្សា **ចំន្ទ សារុន** ស្មៅខ្ញី នៅឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ មកជាសាលាបឋមសិក្សា **ហាំង ម៉ៅ** ស្មៅខ្ញី វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ នេះតទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋាន ផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវ ប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកបាទី នាយកសាលាបឋមសិក្សា **ហាំង ម៉ៅ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គា សាហាន**

* * *